សូមជួយថែរក្សាប្រភេទត្រីទឹកសាបរបស់យើងដែលកំពុងរងគ្រោះ

PLEASE HELP SAVE OUR ENDANGERED FRESHWATER FISH SPECIES



ត្រីរាពត ឬ ត្រីនាគ
Scleropages formosus
Asian bonytongue

- គេប្រទះឃើញប្រភេទត្រីនេះដោយកំរ នៅតាមបណ្តាជ្រោះមួយចំនួននៅតំបន់ជួរភ្នំក្រវាញប៉ែកខាងត្បូងឆ្ពោះទៅខេត្តកំពត និង នៅតាមបណ្តាព្រែកដែលភ្ជាប់ទៅសមុទ្រក្នុងខេត្តកោះកុង ។
- ប្រភេទត្រីនេះត្រូវបានការពារដោយក្រិត្យច្បាប់លេខ ៣៣ ក្រ.ច. ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ក្នុងមាត្រាទី ១៨ និង មាននៅក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES ។



ត្រីរាជ
Pangasianodon gigas
Mekong giant catfish

- ប្រភេទនេះពីមុនសំបូរនៅតាមទន្លេសាប បឹងទន្លេសាប និង តំបន់ទន្លេមេគង្គ ។ បច្ចុប្បន្ននេះ គេប្រទះឃើញមានតិចតួចបំផុតនៅក្នុងដែនទេសាទ ។
- ប្រភេទត្រីនេះត្រូវបានការពារដោយក្រិត្យច្បាប់លេខ ៣៣ ក្រ.ច. ចុះ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ក្នុងមាត្រាទី ១៨ និង មាននៅក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES ។



ត្រីគល់រាំង ឬ ត្រីកាហោ
Catlocapio siamensis
Giant barb

- ប្រភេទត្រីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា
- ប្រភេទនេះពីមុនសំបូរនៅតាមទន្លេសាប បឹងទន្លេសាប និង តំបន់ទន្លេមេគង្គ ។ បច្ចុប្បន្ននេះ គេប្រទះឃើញមានដោយកំរបំផុតនៅក្នុងដែនទេសាទ ។
- ប្រភេទត្រីនេះត្រូវបានការពារដោយក្រិត្យច្បាប់លេខ ៣៣ ក្រ.ច. ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ក្នុងមាត្រាទី ១៨ ។



ត្រីត្រសក់ស
Probarbus labeamajor
Seven-line barb

- ប្រភេទនេះពីមុនសំបូរនៅតាមទន្លេសាប បឹងទន្លេសាប និង តំបន់ទន្លេមេគង្គ ។ បច្ចុប្បន្ននេះ គេប្រទះឃើញមានដោយកំរបំផុតនៅក្នុងដែនទេសាទ ។
- ប្រភេទត្រីនេះត្រូវបានការពារដោយក្រិត្យច្បាប់លេខ ៣៣ក្រ.ច. ចុះថ្ងៃ ទី ៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ក្នុងមាត្រាទី ១៨ និង មាននៅក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES ។



ត្រីត្រសក់
Probarbus labeaminor
Thicklip barb

- ប្រភេទនេះពីមុនសំបូរនៅតាមទន្លេសាប បឹងទន្លេសាប និង តំបន់ទន្លេមេគង្គ ។ បច្ចុប្បន្ននេះ គេប្រទះឃើញមានដោយកំរបំផុតនៅក្នុងដែនទេសាទ ។
- ប្រភេទត្រីនេះត្រូវបានការពារដោយក្រិត្យច្បាប់លេខ ៣៣ក្រ.ច. ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ក្នុងមាត្រាទី ១៨ ។



ត្រីត្រសក់
Probarbus jullieni
Thinlip barb

- ប្រភេទនេះពីមុនសំបូរនៅតាម ទន្លេសាប បឹងទន្លេសាប និង តំបន់ទន្លេមេគង្គ ។ បច្ចុប្បន្ននេះ គេប្រទះឃើញមានដោយកំរបំផុតនៅក្នុងដែនទេសាទ ។
- ប្រភេទត្រីនេះត្រូវបានការពារដោយក្រិត្យច្បាប់លេខ ៣៣ ក្រ.ច. ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ក្នុងមាត្រាទី ១៨ ។



ត្រីកុះឡៀវ ឬ ត្រីកញ្ជ្រៀវ
Puntioplites bulu

- ប្រភេទនេះពីមុនសំបូរនៅតាមបឹងបួរ ទន្លេសាប និង បឹងទន្លេសាប ។ បច្ចុប្បន្ន គេប្រទះឃើញមានដោយកំរនៅក្នុងដែនទេសាទ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ដែលជាហេតុភាពនឹងត្រូវចុះបញ្ជីក្នុងអនុសញ្ញា IUCN ។



ត្រីខ្លា ឬ ត្រីកន្ធប់ខ្លា
Datnioides microlepis
Finescale tigerfish

- ប្រភេទត្រីនេះពីមុនសំបូរនៅតាមស្ទឹង បឹងបួរ និង ទន្លេ ។ បច្ចុប្បន្ន គេកំរប្រទះឃើញត្រីនេះណាស់នៅក្នុងដែនទេសាទ ជាពិសេសនៅតាមទន្លេសាប និង បឹងទន្លេសាប ហើយប្រភេទត្រីនេះ កំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីខ្លា ឬ ត្រីកន្ធប់ខ្លា
Datnioides quadrifasciatus
Barred tigerfish

- ប្រភេទត្រីនេះពីមុនសំបូរនៅតាមពាម ស្ទឹង បឹងបួរ បឹងទន្លេសាប និង ទន្លេ ។ បច្ចុប្បន្ន គេកំរប្រទះឃើញត្រីនេះណាស់នៅក្នុងដែនទេសាទ ជាពិសេសនៅតាមបឹងទន្លេសាប ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីកៀតស្រង់
Balantiocheilos melanopterus
Bala sharkminnow

- ប្រភេទត្រីនេះពីមុនសំបូរនៅតាមទន្លេសាប និង បឹងទន្លេសាប ។ បច្ចុប្បន្ន គេប្រទះឃើញត្រីនេះដោយកំរនៅក្នុងដែនទេសាទ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីខ្លាបីកំណាត់
Systomus partipenzona

- ជាប្រភេទដែលសំបូរនៅតាមព្រែក អូរ និង តំបន់ទូទៅនៃទន្លេមេគង្គក្រោម ។ បច្ចុប្បន្ន គេប្រទះឃើញត្រីនេះដោយកំរនៅក្នុងដែនទេសាទ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីស្នួក
Wallago leeri

- ជាប្រភេទត្រីដែលមាននៅតំបន់ទន្លេមេគង្គលើ ក្នុងខេត្តស្ទឹងត្រែង និងរតនគិរី ជាពិសេសតាមទន្លេសេសាន និង ទន្លេស្រែពក ។ បច្ចុប្បន្ន គេប្រទះឃើញត្រីនេះមានតិចតួចបំផុតនៅក្នុងដែនទេសាទ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីក្របី
Glatothorax fuscus

- ជាប្រភេទត្រីដែលមាននៅតាមតំបន់ទន្លេមេគង្គលើ ។ បច្ចុប្បន្ន គេកំរប្រទះឃើញត្រីនេះណាស់ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីក្របី
Bagarius suchus
Crocodile catfish

- ជាប្រភេទត្រីដែលមាននៅតាមតំបន់ទន្លេមេគង្គលើ ប៉ែកខាងជើងប្រទេស ។ បច្ចុប្បន្ន គេកំរប្រទះឃើញត្រីនេះណាស់ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីក្របី
Bagarius bagarius
Dwarf goonch

- ជាប្រភេទត្រីដែលសំបូរនៅតាមតំបន់ទន្លេមេគង្គលើកន្លែងទឹកជ្រៅ និង អន្លង់ថ្ម ។ បច្ចុប្បន្ន គេកំរប្រទះឃើញត្រីនេះណាស់ ហើយប្រភេទត្រីនេះកំពុងឈានទៅរកការវិនាសផុតពូជ ។



ត្រីក្បក
Tenualosa thibaudeaui
Laotian shad

- ប្រភេទត្រីនេះគេប្រទះឃើញសំបូរនៅក្នុងអាងទន្លេមេគង្គ និង តំបន់បឹងទន្លេសាប ។ បច្ចុប្បន្ន ប្រភេទត្រីនេះគេប្រទះឃើញមានដោយកំរនៅក្នុងដែនទេសាទ ។



ត្រីត្រចៀកដំរី
Osphronemus gouramy
Giant gourami

- ជាប្រភេទត្រីដែលរស់នៅក្នុងតំបន់ទន្លេមេគង្គលើ ក្នុងខេត្តស្ទឹងត្រែង និង រតនគិរី និង ជ្រលងជ្រោះនៃភ្នំក្រវាញក្នុងខេត្តពោធិសាត់ ។ បច្ចុប្បន្ន គេបានប្រទះឃើញត្រីនេះមានតិចតួចនៅតំបន់ទន្លេមេគង្គលើ ។



ត្រីរមាស
Osphronemus exodon
Elephant ear gourami

- ជាប្រភេទដែលរស់នៅក្នុងតំបន់ទន្លេមេគង្គលើ ប៉ែកខាងជើងប្រទេស តាមអន្លង់ជ្រៅៗ និង តាមតំបន់ព្រៃលិចទឹកនៅរដូវវស្សា ។ បច្ចុប្បន្ន គេបានប្រទះឃើញមានតិចតួចនៅក្នុងដែនទេសាទ ។



ត្រីចាស៊ីអ៊ី
Mekongina erythrospila

- ប្រភេទត្រីនេះឃើញមានតែនៅតំបន់មេគង្គលើ ប៉ែកខាងជើងប្រទេសកម្ពុជា តាមដងទន្លេស្រែពក ជាពិសេសក្នុងខេត្តស្ទឹងត្រែង ។ បច្ចុប្បន្ន គេបានប្រទះឃើញមានតិចតួចនៅក្នុងដែនទេសាទ ។



ត្រីឆ្មាក្រពើ
Lycothrissa crocodilus
Sabertooth thryssa

- ប្រភេទត្រីនេះឃើញមាននៅក្នុងទន្លេសាប បឹងទន្លេសាប និង តំបន់ដីសណ្តរទន្លេមេគង្គ ។ បច្ចុប្បន្ន គេប្រទះឃើញប្រភេទត្រីនេះមានដោយកំរនៅក្នុងដែនទេសាទ ។



ត្រីឆ្កោកឆ្នុយ
Albulichthys albuloides

- ប្រភេទត្រីនេះឃើញមាននៅក្នុងទន្លេសាប បឹងទន្លេសាប និង ទន្លេមេគង្គ ។ បច្ចុប្បន្ន គេប្រទះឃើញប្រភេទត្រីនេះមានដោយកំរនៅក្នុងដែនទេសាទ ។

សហការផលិតដោយ នាយកដ្ឋានជលផល និង JICA ២០០៦
ឧបត្ថម្ភការបោះពុម្ពដោយ
ADB TA 4563-CAM: Capacity-Building of Inland Fisheries Research and Development Institute (Phase2)
Adapted from JICA Project
អាស័យដ្ឋាន : អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ : ០២៣ ២១៥ ៤៧០ Email : ifredi@online.com.kh; http://www.ifredi.org